ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ អង្គារ ៣ រោច ខែ ភទ្របទ ឆ្នាំ ខាល ត្រីស័ក ព.ស ២៥៦៦*
*រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០២២*

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីជំនួបពិភាក្សាការងាររវាងឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយឯកឧត្តម គ្រីស ភីតធឺរ (Kriss Peeters) អនុប្រធានធនាគារវិនិយោគអឺរ៉ុប

នៅរសៀលថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០២២, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលជួបឯកឧត្តម Kriss Peeters អនុប្រធានធនាគារវិនិយោគអឺរ៉ុប (European Investment Bank - EIB) ក្នុងដំណើរទស្សនកិច្ចរបស់ឯកឧត្តម មកប្រទេសកម្ពុជា ចាប់ពីថ្ងៃទី ១០ ដល់ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០២២ ។

ជាមួយនឹងកិច្ចស្វាគមន៍យ៉ាងកក់ក្តៅចំពោះចំពោះដំណើរទស្សនកិច្ចរបស់ឯកឧត្តម Kriss Peeters មកកម្ពុជា, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហប្រតិបត្តិការដ៏ល្អប្រសើររវាងរាជរដ្ឋាភិបាលកម្ពុជា និង EIB នាពេលកន្លងមក និងបានបញ្ជាក់ជូនថា រាជរដ្ឋាភិបាលកម្ពុជា បានដាក់ឱ្យប្រើប្រាស់នូវ ***"ក្របខណ្ឌយុទ្ធសាស្រ្ត និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣"*** ជាមួយនិងទស្សនវិស័យនៃការចាកចេញពីវិបត្តិនៃជំងឺកូវីដ-១៩ ក្នុងភាពរឹងមាំ និងការវិលត្រលប់ទៅរកមាគ៌ានៃកំណើន និងការអភិវឌ្ឍប្រកបដោយចីរភាព ។ ***"យុទ្ធសាស្រ្ត"*** នេះ បាន និងកំពុងដើរតួនាទីជាផែនទីបង្ហាញផ្លូវ និងជាកម្លាំងចលករដ៏មានប្រសិទ្ធភាពសម្រាប់ការពង្រឹងសក្តានុពលនៃចន្ទល់កំណើនសេដ្ឋកិច្ចរបស់កម្ពុជាឱ្យរស់រវើកឡើង ក៏ដូចជាចាប់យកឱ្យបាននូវកាលានុវត្តភាពថ្មី ដែលកំពុងលេចឡើងស្របនឹងនិន្នាការតំបន់ និងសកល ដើម្បីលើកកម្ពស់កំណើនប្រកបដោយចីរភាព និងដែលកាន់តែមានពិពិធកម្ម ក៏ដូចជាដើម្បីកសាងភាពធន់ដ៏រឹងមាំនៃសង្គម-សេដ្ឋកិច្ចកម្ពុជា ។ ជាមួយគ្នានេះ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** ក៏បានថ្លែងអំណរគុណចំពោះការគាំទ្ររបស់ EIB ក្នុងការចូលរួមជំរុញកំណើនសេដ្ឋកិច្ចរបស់កម្ពុជា តាមរយៈកិច្ចសហប្រតិបត្តិការបច្ចុប្បន្ន ហើយស្នើសុំឱ្យ EIB បន្តគាំទ្ររាជរដ្ឋាភិបាលក្នុងការវិនិយោគលើវិស័យអាទិភាព តាមរយៈការចូលរួមជាឥណទានសម្បទាន, ហិរញ្ញប្បទានឥតសំណង, និងការគាំទ្រជំនួយបច្ចេកទេសនានា ជាដើម ។

ឯកឧត្តម Kriss Peeters ក៏បានសម្តែងនូវសេចក្តីសោមនស្សរីករាយដែលបានអញ្ជើញមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា និងការស្វាគមន៍ដ៏កក់ក្តៅរបស់រាជរដ្ឋាភិបាលកម្ពុជា និងបានជម្រាបជូនថា EIB បានដាក់សម្ពោធជាផ្លូវការនូវការិយាល័យប្រចាំតំបន់របស់ខ្លួន នៅទីក្រុងចាកាតា ប្រទេសឥណ្ឌូនេស៊ី កាលពីថ្មីនេះ ហើយ EIB បានត្រៀមរួចជាស្រេចក្នុងការពង្រឹងសហប្រតិបត្តិការកម្រិតតំបន់ ជាពិសេស ជាមួយកម្ពុជាឱ្យកាន់តែមានភាពរឹងមាំថែមទៀត ។ **ឯកឧត្តម**

ក៏បានអបអរសាទររាជរដ្ឋាភិបាលកម្ពុជា ដែលធ្វើជាម្ចាស់ផ្ទះសម្រាប់កិច្ចប្រជុំកំពូលអាស៊ាន (ASEAN Summit) លើកទី ៤០ និង ៤១ នៅក្នុងខែ វិច្ឆិកា ឆ្នាំ ២០២២ ខាងមុខនេះ ហើយថ្នាក់ដឹកនាំជាន់ខ្ពស់របស់សហភាពអឺរ៉ុបនឹងអញ្ជើញចូលរួមកិច្ចប្រជុំនេះផងដែរ ។

ជាកិច្ចបញ្ចប់, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហការដ៏ល្អ និងស្វាគមន៍ចំពោះការចូលរួមចំណែករបស់ EIB ក្នុងការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចកម្ពុជា ហើយដំណើរទស្សនកិច្ចរបស់**ឯកឧត្តម Kriss Peeters** មកកម្ពុជា ជាសក្ខីភាពនៃជំហរច្បាស់លាស់របស់ EIB ក្នុងការបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយរាជរដ្ឋាភិបាល កម្ពុជាឱ្យកាន់តែរឹងមាំបន្ថែមទៀត ។